# សេចក្តីសង្ខេបប្រតិបត្តិ

# ស្តីពីក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់

ឯកសារនេះ ជាសេចក្តីសង្ខេបប្រតិបត្តិអំពីចំណុចសំខាន់ៗ ដែលលើកមកពិភាក្សានៅក្នុងក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RPF) នេះ។ សេចក្តីសង្ខេបប្រតិបត្តិនេះពុំមានគោលបំណងដើម្បីផ្តល់ជាព័ត៌មានពេញលេញនោះទេ។ ដើម្បីទទួលបានព័ត៌មានពេញលេញ សូមអានក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RPF) ពេញលេញ។

ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះ ត្រូវបានរៀបចំឡើងដោយអគ្គិសនីកម្ពុជា (EDC) សម្រាប់គម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅកម្ពុជា (CSET)។ ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះ នឹងត្រូវអនុវត្តចំពោះរាល់ការវិនិយោគទាំងអស់ដែលទទួលបានហិរញ្ញប្បទាន ក្រោមគម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅកម្ពុជា (CSET) នេះ។ ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះ ត្រូវបានរៀបចំឡើងស្របតាមនីតិវិធីប្រតិបត្តិស្តង់ដារស្តីពីលទ្ធកម្មដីធ្លី និងការដោះស្រាយផលប៉ះពាល់របស់រាជរដ្ឋាភិបាលកម្ពុជា និងស្តង់ដារបរិស្ថាន និងសង្គមផ្នែកទី 5 របស់ធនាគារពិភពលោក (WB's ESS5) ស្តីពីលទ្ធកម្មដីធ្លី ការរឹតត្បិតលើការប្រើប្រាស់ដីធ្លី និងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត។

ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RPF) នេះ ត្រូវបានចាត់ទុកថាជាឯកសាររស់ ហើយត្រូវតែធ្វើការកែប្រែ និងធ្វើបច្ចុប្បន្នភាពទៅតាមស្ថានភាព ឬនៃទំហំសកម្មភាពការងារដែលមានការផ្លាស់ប្តូរជាក់ស្តែង។ ផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP) នឹងត្រូវរៀបចំបង្កើតឡើងនៅពេលដែល និងប្រសិនបើមានភាពចាំបាច់ ដោយធ្វើការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយគ្រួសារដែលរងផលប៉ះពាល់ពីគម្រោង និងធនាគារពិភពលោក។ ផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP) ត្រូវដាក់ជូនធនាគារពិភពលោកពិនិត្យ និងអនុម័ត។

គោលបំណងនៃគម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅកម្ពុជា (CSET) គឺដើម្បីធ្វើឱ្យប្រសើរឡើងនូវបណ្តាញអគ្គិសនីដើម្បីបង្កើនសមត្ថភាព ភាពជឿជាក់ និងប្រសិទ្ធភាពឱ្យកាន់តែប្រសើរឡើង រួមទាំង ការធ្វើសមាហរណកម្មថាមពលកកើតឡើងវិញ និងការនាំចូលថាមពលស្អាត បង្កលក្ខណៈងាយស្រួល និងលើកកម្ពស់ការប្រើប្រាស់យានយន្តអគ្គិសនី (E-mobility) និងជំរុញការវិនិយោគប្រសិទ្ធភាពថាមពលនៅក្នុងវិស័យឧស្សាហកម្ម ដើម្បីគាំទ្រដល់គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល (NEEP)។ គម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅ

កម្ពុជា (CSET) នឹងអនុវត្តតាមរយៈសកម្មភាពផ្សេងៗដោយមានសមាសធាតុចំនួនបី៖ (i) សមាសធាតុទី 1៖ ការពង្រឹងបណ្តាញអគ្គិសនីសម្រាប់សម្របសម្រួលដល់អន្តរកាលថាមពល និងពាណិជ្ជកម្មថាមពលក្នុងតំបន់ (ii) សមាសធាតុទី 2៖ ការវិនិយោគលើប្រសិទ្ធភាពថាមពលឧស្សាហកម្ម និង (iii) សមាសធាតុទី 3៖ ថាមពលស្អាតសម្រាប់ចម្អិនអាហារ និងមានប្រសិទ្ធភាព។

ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះ មានគោលបំណងផ្តល់ការណែនាំសម្រាប់រៀបចំបង្កើតផែនការដោះស្រាយផលប៉ះពាល់ (RPs) សម្រាប់អនុគម្រោងដែលត្រូវកំណត់អត្តសញ្ញាណ និងបញ្ជាក់នៅក្នុងអំឡុងពេលអនុវត្តគម្រោង។ ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RPF) បង្កើតគោលការណ៍សម្រាប់កាដោះស្រាយផលប៉ះពាល់ លក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបាន ម៉ាទ្រីសសិទ្ធិទទួលបាន ការរៀបចំការអនុវត្ត យន្តការដោះស្រាយបណ្តឹងតវ៉ា យន្តការផ្តល់មូលនិធិ និងការរៀបចំការពិនិត្យតាមដាន និងការវាយតម្លៃ។

ហានិភ័យបរិស្ថាន និងសង្គមសំខាន់ៗដែលពាក់ព័ន្ធនឹងសមាសធាតុគម្រោងនីមួយៗ រួមមានដូចខាងក្រោម៖

- សមាសធាតុទី 1៖ ការពង្រឹងបណ្តាញអគ្គិសនីសម្រាប់ធ្វើអន្តរកាលថាមពល៖ ខ្សែបញ្ជូនអគ្គិសនី និងអនុស្ថានីយអគ្គិសនី អាចតម្រូវឱ្យមានការធ្វើលទ្ធកម្មដីធ្លី និងការដោះស្រាយផលប៉ះពាល់ដែលបង្កឱ្យមានផលប៉ះពាល់ពីការសាងសង់ ដូចជា សំឡេងរំខាន ធូលី និងការបង្កើតកាកសំណល់។ ប្រព័ន្ធផ្ទុកថាមពលថ្ម (BESS) បង្កើតឱ្យមានកាកសំណល់គ្រោះថ្នាក់ និងហានិភ័យសុវត្ថិភាពអគ្គិភ័យ ខណៈពេលដែលការកសាងហេដ្ឋារចនាសម្ព័ន្ធ EV អាចបង្កផលប៉ះពាល់ដល់នគរូបនីយកម្ម និងអាចតម្រូវឱ្យមានការធ្វើវិសោធនកម្មច្បាប់។ អគ្គិសនីភាវូបនីយកម្មនៅជនបទនៅក្រោមអនុសមាសធាតុ 1.5 អាចទាមទារឱ្យមានការឈូសឆាយដី និងការរំខានដល់សហគមន៍មូលដ្ឋាន និងវិស័យកសិកម្ម។

- សមាសធាតុទី 2៖ ប្រសិទ្ធភាពថាមពលឧស្សាហកម្ម៖ លើកកម្ពស់បច្ចេកវិទ្យាមានប្រសិទ្ធភាពថាមពល ដែលកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ប៉ុន្តែអាចបណ្តាលឱ្យមានការរំខានដល់កម្លាំងពលកម្ម និងហានិភ័យផ្នែកសុវត្ថិភាព និងសុខភាព (OHS) ក្នុងអំឡុងពេលដំឡើងសម្ភារទាំងនេះ។

- សមាសធាតុទី 3៖ ថាមពលស្អាតសម្រាប់ចម្អិនអាហារ និងមានប្រសិទ្ធភាព៖ លើកកម្ពស់បច្ចេកវិទ្យាមានប្រសិទ្ធភាពថាមពល ដែលកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់

ប៉ុន្តែអាចបណ្តាលឱ្យមានការរំខានដល់កម្លាំងពលកម្ម និងហានិភ័យផ្នែកសុវត្ថិភាព និងសុខភាព (OHS) ក្នុងអំឡុងពេលដំឡើងសម្ភារទាំងនេះ។

មានតែសមាសធាតុទី 1 ប៉ុណ្ណោះដែលអាចមានជាប់ពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី និងការដោះស្រាយផលប៉ះពាល់ជារូបវន្ត។ ខ្សែបញ្ជូនអគ្គិសនី និងអនុស្ថានីយអគ្គិសនី អាចតម្រូវឱ្យមានការធ្វើលទ្ធកម្មដីធ្លី និងការដោះស្រាយផលប៉ះពាល់ ដែលបង្កឱ្យមានផលប៉ះពាល់ពីការសាងសង់ ដូចជា សំឡេងរំខាន ធូលី និងការបង្កើតកាកសំណល់។ ប្រព័ន្ធផ្ទុកថាមពលថ្ម (BESS) បង្កើតឱ្យមានកាកសំណល់គ្រោះថ្នាក់ និងហានិភ័យសុវត្ថិភាពអគ្គិភ័យ ខណៈពេលដែលការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ EV អាចបង្កផលប៉ះពាល់ដល់នគរូបនីយកម្ម និងអាចតម្រូវឱ្យមានការធ្វើវិសោធនកម្មច្បាប់។ អគ្គិសនីភាវូបនីយកម្មនៅជនបទនៅក្រោមអនុសមាសធាតុ 1.5 អាចតម្រូវឱ្យមានការឈូសឆាយដី និងការរំខានដល់សហគមន៍មូលដ្ឋាន និងវិស័យកសិកម្ម។ សមាសធាតុទី 2 ពុំមានជាប់ពាក់ព័ន្ធនឹងការធ្វើលទ្ធកម្មដីធ្លី និងការដោះស្រាយផលប៉ះពាល់ជារូបវន្តឡើយ។

ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះ អនុវត្តចំពោះការតាំងទីលំនៅឡើងវិញជារូបវន្តជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ន និងការផ្លាស់ប្តូរទីតាំងផ្នែកសេដ្ឋកិច្ច ដែលបណ្តាលដោយផ្ទាល់ពីគម្រោង និងអនុលោមតាមស្តង់ដារបរិស្ថាន និងសង្គមផ្នែកទី 5 (ESS5) របស់ធនាគារពិភពលោក (WB)។ គ្រួសារដែលរងផលប៉ះពាល់ទាំងអស់ពីគម្រោង ដែលមានទ្រព្យសម្បត្តិនៅក្នុងរបៀងផលប៉ះពាល់ផ្ទាល់ (COI) មុនកាលកាលបរិច្ឆេទកំណត់ (Cut-Off-Date) នឹងមានសិទ្ធិទទួលបានសំណង ដូចដែលមានពណ៌នានៅក្នុងក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RPF) នេះ ដោយមិនគិតអំពីស្ថានភាពស្របច្បាប់របស់ពួកគេនោះឡើយ។ កាលបរិច្ឆេទកំណត់ (COD) នឹងបង្កើតឡើង ចងក្រងឯកសារ និងផ្សព្វផ្សាយនៅទូទាំងតំបន់អនុគម្រោងតាមរយៈការបិទផ្សព្វផ្សាយនៅលើផ្ទាំងផ្សព្វផ្សាយព័ត៌មានជាសាធារណៈ និងនៅសាលាឃុំ។ កាលបរិច្ឆេទកំណត់ (COD) សម្រាប់គម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅកម្ពុជា (CSET) ត្រូវបានកំណត់ថាជាថ្ងៃចុងក្រោយនៃការពិគ្រោះយោបល់ជុំទីមួយ ដែលនឹងធ្វើឡើងជាមួយប្រជាជនក្នុងមូលដ្ឋាន បន្ទាប់ពីបានធ្វើការផ្សព្វផ្សាយអំពីរបៀងផលប៉ះពាល់ផ្ទាល់ (COI) របស់គម្រោង។ គោលបំណងនៃកាលបរិច្ឆេទកំណត់ (COD) គឺដើម្បីការពារអគ្គិសនីកម្ពុជា (EDC) ពីការទាមទារណាមួយដោយបុគ្គលទទួលបានសិទ្ធិអនុញ្ញាត និងកាត់បន្ថយកត្តាជំរុញឱ្យមានការទិញដីធ្លីទុកចំណេញ និងសម្រាប់ប្រជាជនផ្លាស់ទីលំនៅចូលទៅទីតាំងលំនៅក្នុងតំបន់គម្រោងដោយសង្ឃឹមថានឹងទទួលបានសំណង។ កាលបរិច្ឆេទកំណត់ (COD) ត្រូវតែចងក្រងជាឯកសារឱ្យបានគ្រប់គ្រាន់។ បុគ្គលដែលមិនមានឈ្មោះត្រូវទទួលសំណង អាចមានសិទ្ធិទទួលសំណង ប្រសិនបើពួកគេអាចបង្ហាញភស្តុតាងថាពួកគេមិនបានទទួលព័ត៌មានគ្រប់គ្រាន់នៅក្នុងអំឡុងពេលធ្វើជំរឿនគម្រោង។

ការធ្វើលទ្ធកម្មដីធ្លីសម្រាប់គម្រោងនេះ ត្រូវធ្វើឡើងតាមរយៈដំណោះស្រាយផលប៉ះពាល់ដោយមានការចរចា។ ក្នុងករណីដែលការដោះស្រាយផលប៉ះពាល់ដោយការចរចាមិនអាចទទួលយកដោយគ្រួសារដែលរងផលប៉ះពាល់ពីគម្រោង ឬមិនអាចទទួលបានជោគជ័យ នោះអគ្គិសនីកម្ពុជា (EDC) នឹងរៀបចំផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP) ស្របតាមក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះ ដើម្បីដាក់ជូនធនាគារពិភពលោកពិនិត្យជាមុន។ ការអង្កេតជំរឿននេះ នឹងគ្របដណ្តប់លើជនដែលរងផលប៉ះពាល់ (APs) ទាំង 100%។ ការអង្កេតវាស់វែងលម្អិត (DMS) នឹងធ្វើឡើងជាមួយជនដែលរងផលប៉ះពាលទាំង 100% ហើយត្រូវធ្វើឡើងដោយការិយាល័យសង្គម បរិស្ថាន និងទំនាក់ទំនងសាធារណៈ (SEPRO) ដោយទទួលបាន ការគាំទ្រពីទីប្រឹក្សាអនុវត្តគម្រោង (PIC) ក្រោមកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធ។ ការសិក្សាពីថ្លៃជំនួស (RCS) នឹងធ្វើឡើងស្របគ្នាជាមួយ ការអង្កេតវាស់វែងលម្អិត (DMS) ដោយភ្នាក់ងារឯករាជ្យដែលនឹងជ្រើសរើសឱ្យបំពេញការងារនេះ ដោយអគ្គិសនីកម្ពុជា (EDC)។ ស្តង់ដារបរិស្ថាន និងសង្គមផ្នែកទី 5 របស់ធនាគារពិភពលោក បានបង្ហាញថា នៅក្នុងកាលៈទេសៈខ្លះ មានអាចមានការស្នើឡើងថា ដីធ្លីផ្នែកខ្លះ ឬទាំងអស់ ដែលនឹងប្រើប្រាស់ដោយគម្រោង គឺត្រូវបានបរិច្ចាគដោយស្ម័គ្រចិត្តដោយមិនចាំបាច់ផ្តល់សំណងពេញលេញនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ការបរិច្ចាគដោយស្ម័គ្រចិត្តនេះ មិនអនុវត្តនៅក្រោមគម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅកម្ពុជា (CSET) នោះទេ។ អគ្គិសនីកម្ពុជា (EDC) នឹងផ្តល់សំណងដល់ជនដែលរងផលប៉ះពាល់ទាំងអស់ចំពោះរាល់ការខាតបង់ទាំងអស់ដែលមាន ដោយស្របតាមក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់។

អគ្គិសនីកម្ពុជា (EDC) គឺជាស្ថាប័នអនុវត្តគម្រោង ដែលទទួលខុសត្រូវចំពោះសមាសធាតុទី 1 តាមរយៈអង្គភាពគ្រប់គ្រងគម្រោង (PMU) និងការិយាល័យគ្រប់គ្រងគម្រោង (PMO) របស់ខ្លួន។ ក្រសួងរ៉ែ និងថាមពល (MME) គឺជាស្ថាប័នទទួលខុសត្រូវចំពោះសមាសធាតុទី 2 ដែលពុំមានពាក់ព័ន្ធ នឹងការធ្វើលទ្ធកម្មដីធ្លីនោះទេ។ ប្រសិនបើមានការតាំងទីលំនៅឡើងវិញ និងការធ្វើលទ្ធកម្មដីធ្លីដោយមិនស្ម័គ្រចិត្ត នោះអគ្គិសនីកម្ពុជា (EDC) នឹងធ្វើការដោះស្រាយផលប៉ះពាល់ និងការធ្វើលទ្ធកម្មដីធ្លីស្របតាមគោលនយោបាយ និងនីតិវិធីនៅក្នុងក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ (RPF) នេះ។

អគ្គិសនីកម្ពុជា (EDC) នឹងរៀបចំបង្កើតគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា (GRC) ភ្លាមៗនៅពេលដែលគម្រោងចាប់ផ្តើមអនុវត្ត។ គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា (GRC) នឹងដំណើរការចាប់ពីដំណាក់កាលសាងសង់រហូតដល់ដំណាក់កាលប្រតិបត្តិការ។ ដូចដែលបានអនុវត្តកន្លងមក

គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា (GRC) នឹងរួមមានសមាសធាតុមេឃុំ និង/ឬ មេភូមិនៅក្នុងមូលដ្ឋានដែលពាក់ព័ន្ធ ដែលមានការិយាល័យគ្រប់គ្រងគម្រោង (PMO) ជាប្រធាន និងទទួលបានជំនួយពីការិយាល័យសង្គម បរិស្ថាន និងទំនាក់ទំនងសាធារណៈ (SEPRO) និងទីប្រឹក្សាអនុវត្តគម្រោង (PIC) នៅក្នុងរយៈពេលកិច្ចសន្យាពីដើមដល់ចប់ ហើយអាចមានសមាជិកផ្សេងទៀត រួមមាន មន្ត្រីថ្នាក់ខេត្ត ឬបុគ្គលដែលត្រូវបានតែងតាំងដោយថ្នាក់ខេត្ត មន្ត្រីថ្នាក់ស្រុកមកពីការិយាល័យសុរិយោដី ឬបុគ្គលដែលខ្លួនតែងតាំង អ្នកម៉ៅការសាងសង់ និងសាក្សីរបស់ជនដែលរងផលប៉ះពាល់ ហើយគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា (GRC) យ៉ាងតិចមានសមាជិកម្នាក់ជាស្ត្រី។ ការិយាល័យសង្គម បរិស្ថាន និងទំនាក់ទំនងសាធារណៈ (SEPRO) នឹងរក្សាកំណត់ត្រានៃបណ្តឹងតវ៉ាទាំងអស់ដែលពាក់ព័ន្ធនឹងគម្រោង ហើយនឹងធ្វើការតាមដានយ៉ាងជិតដល់ និងទៀងទាត់ទៅលើដំណើរការដោះស្រាយបណ្តឹងតវ៉ាដើម្បីធានា ឱ្យបាននូវការផ្តល់ដំណោះស្រាយទាន់ពេលវេលា។

ថ្លៃចំណាយសម្រាប់រាល់ការធ្វើលទ្ធកម្មដីធ្លីទាំងអស់ សំណង ជំនួយសម្រាប់ការតាំងទីលំនៅឡើងវិញ រួមទាំង ថ្លៃចំណាយលើការអនុវត្តកម្មវិធីស្តារប្រាក់ចំណូល ឬគាំទ្រណាមួយ ប្រសិនបើចាំបាច់សម្រាប់គម្រោងនេះ នឹងផ្តល់ហិរញ្ញប្បទានពីអគ្គិសនីកម្ពុជា (EDC)។ ថ្លៃចំណាយលើផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP) ក៏នឹងបែងចែកចេញពីថវិកាអគ្គិសនីកម្ពុជា (EDC) ផងដែរ។ ថ្លៃចំណាយនេះ នឹងមិនត្រូវផ្តល់ហិរញ្ញប្បទានណាមួយពីប្រាក់ឥណទានគម្រោង ដែលផ្តល់ដោយធនាគារពិភពលោកនោះទេ។ ក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា (EDC) នឹងអនុម័តផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP) ដែលបានរៀបចំឡើងសម្រាប់គម្រោង ហើយដោយផ្អែកលើសកម្មភាពនេះ ការបែងចែកថវិកាសម្រាប់អនុវត្តផែនការដោះស្រាយផលប៉ះពាល់លម្អិត (DRP) នឹងត្រូវរៀបចំឡើង។ អគ្គិសនីកម្ពុជា (EDC) តាមរយៈ ការិយាល័យសង្គម បរិស្ថាន និងទំនាក់ទំនងសាធារណៈ (SEPRO) នឹងផ្តល់សំណង និងសំណងពេញសិទ្ធិទទួលបានផ្សេងៗជូនជនដែលរងផលប៉ះពាល់ និងធ្វើប្រតិបត្តិការពាក់ព័ន្ធផ្សេងទៀត រួមទាំងប្រតិបត្តិការដែលពាក់ព័ន្ធនឹងការកែតម្រូវបណ្ណសម្គាល់កម្មសិទ្ធិ ការជ្រើសរើសទីប្រឹក្សាឯករាជ្យសិក្សាតន្លៃជំនួស RCS។ ថវិកា DRP នឹងរួមបញ្ចូលទាំង ការចំណាយលើសំណង ជំនួយ ការស្តារប្រាក់ចំណូលឡើងវិញ ប្រសិនបើចាំបាច់ ការជ្រើសរើសទីប្រឹក្សាឯករាជ្យសិក្សាតន្លៃជំនួស RCS ការចំណាយរដ្ឋបាល និងថវិកាសម្រាប់យថាភាព។ អគ្គិសនីកម្ពុជា (EDC) ជាស្ថាប័នទទួលខុសត្រូវក្នុងការបែងចែកថវិកាឱ្យគ្រប់គ្រាន់ និងទាន់ពេលវេលាដើម្បីធានាបាននូវការអនុវត្ត DRP ប្រកបដោយភាពរលូន។

អគ្គិសនីកម្ពុជា (EDC) ត្រូវទទួលខុសត្រូវក្នុងការពិនិត្យតាមដានការអនុវត្តជារួមនូវគម្រោងអន្តរកាលថាមពលប្រកបដោយនិរន្តរភាពនៅកម្ពុជា (CSET) ដំណើរការ និងលទ្ធផលនៃសកម្មភាពគម្រោង ដូចដែលមានចែងនៅក្នុងក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះ។ អគ្គិសនីកម្ពុជា (EDC) ធានាថា ការចរចាណាមួយជាមួយជនដែលត្រូវបានផ្លាស់ប្តូរទីលំនៅនឹងត្រូវដោះស្រាយដោយបើកចំហានូវហានិភ័យមិនស៊ីសង្វាក់គ្នានៃព័ត៌មាន និងអំណាចចរចារបស់ភាគីនានាដែលពាក់ព័ន្ធនៅក្នុងប្រតិបត្តិការទាំងនេះ។ អគ្គិសនីកម្ពុជា (EDC) នឹងធានាថារាល់ការទូទាត់សំណង/ការរៀបចំទាំងអស់ រួមទាំងការដោះស្រាយផលប៉ះពាល់ដោយការចរចាណាមួយ គឺធ្វើឡើងដោយ ផ្អែកលើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយជនដែលរងផលប៉ះពាល់ រួមទាំង ជនដែលគ្មានបណ្ណសម្គាល់កម្មសិទ្ធិស្របច្បាប់ចំពោះទ្រព្យសម្បត្តិនានាផងដែរ។ ការដោះស្រាយផលប៉ះពាល់ដោយការចរចា នឹងផ្តល់តម្លៃគ្រប់គ្រាន់ និងយុត្តិធម៌សម្រាប់ដីធ្លី និង/ឬទ្រព្យសម្បត្តិផ្សេងទៀត។ អគ្គិសនីកម្ពុជា (EDC) នឹងជ្រើសរើសទីប្រឹក្សាអនុវត្តគម្រោង (PIC) ឱ្យជួយរៀបចំចងក្រងជាឯកសារនូវកត់ត្រាដំណើរការចរចា និងការដោះស្រាយផលប៉ះពាល់។ អគ្គិសនីកម្ពុជា (EDC) នៅតែជាស្ថាប័នទទួលខុសត្រូវចំពោះការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍អំពីការអនុវត្តសកម្មភាពធ្វើលទ្ធកម្មដីធ្លី ប្រសិនបើមាន។